**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០២៣-១១៥ ពក.ណន

ថ្ងៃ សុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ ធ្នូ ឆ្នាំ២០២៣

# សេចក្តីណែនាំ
# លើការអនុវត្តប្រតិបត្តិការ
# ផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)

យោងសេចក្តីជូនដំណឹងលេខ ធ១.០១៦.០៥៤.ពិសេស ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់អំពីលក្ខខណ្ឌចាំបាច់និងនីតិវិធីមួយចំនួនក្នុងការចូលរួមដេញថ្លៃប្រតិបត្តិការ LPCO ដូចតទៅ៖

**ក- លក្ខខណ្ឌចាំបាច់មុនពេលដេញថ្លៃ**

- ត្រូវចុះកិច្ចសន្យាជាមួយធនាគារជាតិនៃកម្ពុជា លើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញរបស់ធនាគារជាតិនៃកម្ពុជា
- ត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់ផ្លែតហ្វមធនាគារជាតិនៃកម្ពុជា (NBCP)
- ត្រៀមបម្រុងមូលបត្រអាចជួញដូរបាន (NCD) និង/ឬ មូលបត្ររដ្ឋ សម្រាប់ធានាប្រតិបត្តិការ LPCO ដែលទទួលបានជោគជ័យក្នុងការដេញថ្លៃ
- តណប្រតិទានរបស់មូលបត្រអាចជួញដូរបាន (NCD) និង/ឬ មូលបត្ររដ្ឋ ត្រូវតែធំជាង ឬស្មើនឹងតណប្រតិទានរបស់ប្រតិបត្តិការ LPCO
- តម្លៃចារឹកមូលបត្រអាចជួញដូរបាន (NCD) និង/ឬ មូលបត្ររដ្ឋ ត្រូវតែធំជាងឬស្មើទំហំទឹកប្រាក់របស់ LPCO។ ចំពោះ មូលបត្រអាចជួញដូរបាន (NCD) ជាប្រាក់ដុល្លារអាមេរិកដែលនឹងដាក់ធានាលើទំហំទឹកប្រាក់ LPCO នឹងត្រូវអនុវត្ត Haircut លើតម្លៃចារឹក ក្នុងកម្រិតមួយដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

**ខ- នីតិវិធីក្នុងការដាក់ដេញថ្លៃ**

- ទំហំទឹកប្រាក់ដេញថ្លៃអតិបរមា/អប្បបរមាក្នុងមួយគ្រឹះស្ថាន អត្រាការប្រាក់អប្បបរមាសម្រាប់តណប្រតិទាននីមួយៗ កម្រិត Haircut សម្រាប់មូលបត្រអាចជួញដូរបាន (NCD) ជាប្រាក់ដុល្លារអាមេរិក និងនីតិវិធីពាក់ព័ន្ធដទៃទៀតនឹងត្រូវជូនដំណឹងមុនថ្ងៃដេញថ្លៃ
- ការដាក់ដេញថ្លៃនឹងប្រព្រឹត្តទៅចាប់ពីម៉ោង ៨:០០ នាទីព្រឹក រហូតដល់ម៉ោង ១១:០០ នាទីព្រឹក ហើយត្រូវធ្វើឡើងតាមប្រព័ន្ធ NBCP។ ក្នុងករណីមិនអាចអនុវត្តបានតាមប្រព័ន្ធ NBCP ការដាក់



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ដេញថ្លៃត្រូវធ្វើតាមសារអេឡិចត្រូនិក Bod.lpco@nbc.gov.kh ឬដាក់ក្នុងស្រោមសំបុត្របិទជិត ហើយផ្ញើទៅនាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា

- លទ្ធផលនៃការដេញថ្លៃ នឹងប្រកាសនៅម៉ោង ២:០០ នាទីរសៀល នាថ្ងៃដេញថ្លៃ
- គ្រឹះស្ថានដែលដាក់ដេញថ្លៃតាមប្រព័ន្ធ NBCP ហើយទទួលជោគជ័យ នឹងត្រូវទទួលបានលិខិតបញ្ជាក់លទ្ធផលព្រមទាំងព័ត៌មានពាក់ព័ន្ធពីប្រព័ន្ធ NBCP។ គ្រឹះស្ថានដែលដាក់ដេញថ្លៃតាមសារអេឡិចត្រូនិក ឬតាមស្រោមសំបុត្រ ត្រូវចុះកិច្ចសន្យាបំពេញបន្ថែមជាមួយធនាគារជាតិនៃកម្ពុជា។

**គ- នីតិវិធីក្រោយពេលដេញថ្លៃឈ្នះ**

- នៅថ្ងៃទូទាត់ គ្រឹះស្ថានដែលទទួលជោគជ័យក្នុងការដេញថ្លៃនឹងទទួលបានសន្ទនីយភាព បន្ទាប់ពីបានចុះកិច្ចសន្យាផ្ទេរសិទ្ធិកាន់កាប់មូលបត្រអាចជួញដូរបាន (NCD) និង/ឬ មូលបត្ររដ្ឋ ជូនធនាគារជាតិនៃកម្ពុជា។ ក្នុងករណីមិនបានប្រគល់មូលបត្រអាចជួញដូរបាន(NCD) និង/ឬ មូលបត្ររដ្ឋតាមកាលកំណត់ ធនាគារជាតិនៃកម្ពុជា នឹងពិន័យតាមចំនួនសមស្របណាមួយ
- នៅថ្ងៃតណប្រតិទាននៃប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជានឹងផ្ទេរសិទ្ធិកាន់កាប់មូលបត្រ-អាចជួញដូរបាន (NCD) និង/ឬ មូលបត្ររដ្ឋ ជូនភាគីខ្ចីប្រាក់វិញ បន្ទាប់ពីភាគីនេះបានទូទាត់ចប់សព្វគ្រប់នូវទឹកប្រាក់បានខ្ចី និងការប្រាក់ រួមទាំងកាតព្វកិច្ចផ្សេងៗទៀត ប្រសិនបើមាន
- ការប្រាក់បង្គរនឹងត្រូវបានគណនាអាស្រ័យលើទំហំប្រាក់ រយៈពេលខ្ចីប្រាក់ អត្រាការប្រាក់ និងផ្អែកលើមូលដ្ឋានចំនួនថ្ងៃជាក់ស្តែងក្នុងឆ្នាំនីមួយៗ។

សេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា លេខ ធ៥.០២៣.០០៧ ស.ក.ណ.ន ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ត្រូវចាត់ទុកជាមោឃៈចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះតទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជ្រាប និងសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមទំនាក់ទំនង ៖
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣ EXT. ១០៤៨
(៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨
សារអេឡិចត្រូនិក : lpco.info@nbc.gov.kh
បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial ,
www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia ,
www.linkedin.com/company/national-bank-of-cambodia ,
www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA